តាមជំនឿសាសនាធេនរីរបស់យើងខ្ញុំបានបង្រៀនថាមនុស្សម្នាទាំងអស់គឺជាបងប្អូននឹងគ្នា។

ហើយក៏ដូចជាមិត្តភក្តិដែលនៅជុំវិញខ្លួនរបស់ពួកយើងក៏សុទ្ធតែជាបងប្អូនផងដែរ។

ជាពិសេសការធ្វើល្អចំពោះពួកគេតើវាល្អយ៉ាងណាដែរ?

ប៉ុន្តែជាដំបូងគឺការធ្វើអំពើល្អចំពោះអ្នកដែលនៅជុំវិញខ្លួនរបស់អ្នក។

« **ការធ្វើអំពើល្អនឹងទទួលបានផលល្អ** »

អាស័យដ្ឋាន :

# ចិត្តសម្បុរស

やさしさ

ពាក្យថាសុភមង្គល

គឺសំដៅទៅលើថាតើមនុស្សបែបណាខ្លះ

ដែលនៅជុំវិញខ្លួនយើងនិងមនុស្សប៉ុន្មាន

អ្នកដែលយើងអាចពឹងផ្អែកទៅលើបាន ?

ប្រសិនបើមានអ្នករួមសុខទុក្ខនៅពេលដែលយើងជួបទុក្ខឬជួបភាពលំបាកនិងភាពសប្បាយរីករាយផ្សេងៗជាមួយនឹងអ្វីដែលយើងបានជួបដែរនោះមិនដឹងជាល្អយ៉ាងណានោះទេតែសុភមង្គលបែបនោះវាគ្មាននោះទេ...!!!

ផ្ទុយទៅវិញទោះបីជាខ្លួនយើងត្រូវបានជួបការលំបាកហើយត្រូវបានគេនិយាយអោយថា « គ្មានទំនាក់ទំនងទេ! » នឹងមិនអើពើនឹងយើងយ៉ាងណាក៏ដោយក៏មិនមែនប្រាកដថាខ្សែជីវិតរបស់យើងទទួលភាពឯកោនោះដែរ។

កាលណាយើងធ្វើល្អនិងការចេះនិយាយល្អចំពោះអ្នកដទៃនោះយើងក៏នឹងទទួលមកវិញនូវសេចក្តីគោរពនិងសេចក្តីស្រលាញ់ចូលចិត្តពីអ្នកគ្រប់គ្នាវិញផងដែរ។

ទាំងនេះក៏ប្រហែលជាវាសនារបស់មនុស្សរៀងៗខ្លួន។ មនុស្សដែលមិនមានទឹកចិត្តល្អនៅក្នុងខ្លួនគឺមិនស្គាល់នូវតម្លៃនៃទឹកចិត្តល្អរបស់មនុស្សនោះទេ។

ចំណែកឯអ្នកដែលស្គាល់នូវអត្ថន័យនៃទឹកភ្នែករបស់មនុស្សនោះ នោះទើបជាមនុស្សដែលមានទឹកចិត្តល្អពិត។

《 **ត្រូវចេះជួយយកអាសាចំពោះអ្នកនៅជុំវិញខ្លួន** 》របស់អ្នក តើនោះមិនមែនជាទឹកចិត្តសប្បុរសពិតទេឬ ?